ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

*The NGO Forum on Cambodia*

ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង

*Working Together for Positive Change*

**ក្រសួងបរិស្ថាន**

**នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន**

# មគ្គុទ្ទេសក៍នៃ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៅព្រះរាជាណាចក្រកម្ពុជា

**ឆ្នាំផលិត ព.ស ២៥៥៦/គ.ស ២០១២**

# មគ្គុទ្ទេសក៍នៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
# នៅព្រះរាជាណាចក្រកម្ពុជា

## អ្នកផ្តួចផ្តើមគំនិត៖

**១. លោក ពុទ្ធ សូរិទ្ធី** ប្រធាននាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

**២. លោក ឈិត សំអាត** នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

**៣. លោកស្រី ជា ផល្លីកា** មន្ត្រីសម្របសម្រួលគម្រោងសិទ្ធិសហគមន៍ និងទំនប់វារីអគ្គិសនី វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

## អ្នករៀបចំអត្ថបទ៖

**លោក ដាញ់ សេរី** អនុប្រធាននាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## កែសម្រួល និងត្រួតពិនិត្យ៖

មន្ត្រីនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន និងសមាជិកសម្ព័ន្ធទន្លេកម្ពុជា

## អ្នករចនារូបភាព៖

**លោក អ៊ុង វុទ្ធី** ប្រធានការិយាល័យ នៃនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## គាំទ្រថវិកាដោយ៖

**វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា**

# អារម្ភកថា

ការរៀបចំកូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៅព្រះរាជាណាចក្រកម្ពុជានេះ គឺជាសមិទ្ធិផលនៃកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងសម្ព័ន្ធទន្លេកម្ពុជា។

កូនសៀវភៅនេះមានគោលបំណងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធនានា ដើម្បីឲ្យយល់ដឹងពីលិខិតបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅប្រទេសកម្ពុជា។ នៅក្នុងបទដ្ឋានទាំងនេះបង្ហាញពីដំណាក់កាលនៃការជ្រើសរើសគម្រោង កំណត់វិសាលភាពនៃគម្រោង ការវិភាគពីហេតុប៉ះពាល់ វិធានការកាត់បន្ថយ ការរៀបចំរបាយការណ៍ ការពិនិត្យរបាយការណ៍ ការធ្វើសេចក្តីសំរេច និងការអង្កេតតាមដានលើផែនការគ្រប់គ្រងបរិស្ថាន ព្រមទាំងការចូលរួមពីសាធារណជននៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ទិន្នន័យមួយចំនួននៅក្នុងកូនសៀវភៅនេះដកស្រង់ចេញពីឯកសារ របស់កម្មវិធីបរិស្ថាន នៃអង្គការសហប្រជាជាតិ ដោយបញ្ជៀបបញ្ចូលជាមួយអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩ ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងនិងពេញលេញ ឆ្នាំ២០០៩ និងបទដ្ឋានគតិយុត្តនានា របស់ក្រសួងបរិស្ថានដែលពាក់ព័ន្ធនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន** ដែលបានអនុញ្ញាតឲ្យមានកិច្ចសហការជាមួយដៃគូអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផលិត និង បោះពុម្ពកូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះឡើង។

សូមថ្លែងអំណរគុណចំពោះមន្ត្រីរៀបចំការងារ និងមន្ត្រីរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងសមាជិកសម្ព័ន្ធទន្លេកម្ពុជាក្នុងការចូលរួមចំណែកពិនិត្យ និងផ្តល់យោបល់គ្រប់ដំណាក់កាលនៃការរៀបចំកូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ជាចុងក្រោយ សូមថ្លែងអំណរគុណដល់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ចំពោះកិច្ចសហការរៀបចំ និងឧបត្ថម្ភគាំទ្រផ្នែកថវិកាដល់ការរៀបចំកូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះឡើង។

នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
ក្រសួងបរិស្ថាន
#៤៨ សម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

# មាតិកា

**ទំព័រ**


អារម្ភកថា ii
សេចក្តីថ្លែងអំណរគុណ iii
មាតិកា iv
១. សេចក្តីផ្តើម ១
២. បទបញ្ញត្តិទាក់ទងនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ២
៣. កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ៣
៣.១. ស្ថាប័នទទួលខុសត្រូវ ៣
៣.២. គោលការណ៍ និងដំណាក់កាលនៃការវាយតំលៃ
ហេតុប៉ះពាល់បរិស្ថាន ៤
ក. គម្រោងស្នើសុំ ៥
ខ. ការជ្រើសរើសគម្រោង ៥
គ. ការកំណត់វិសាលភាព ៧
ឃ. ការវិភាគហេតុប៉ះពាល់បរិស្ថាន ៨
ង. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ៩
ច. ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ១២
ឆ. ការពិនិត្យ និងការធ្វើសេចក្តីសម្រេចលើរបាយការណ៍ ១៣
ជ. ការអង្កេតតាមដានគម្រោង ១៦
ឈ. ការចូលរួមជាសាធារណៈ ១៧
៤. សេចក្តីសន្និដ្ឋាន ១៩
ឯកសារយោង
ឧបសម្ព័ន្ធ

## ១. សេចក្ដីផ្ដើម

បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសនៅឆ្នាំ១៩៩១ និងការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្ដើមពិចារណាចំពោះការប្រើប្រាស់ធនធានធម្មជាតិ ដែលសំបូរបែបឲ្យមាននិរន្តរភាព។ ក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងធ្វើការយ៉ាងសកម្មក្នុងទិសដៅបង្កើតលេខាធិការដ្ឋានគ្រប់គ្រងបរិដ្ឋាន ដែលជាស្ថាប័នកំពូលក្នុងការដឹកនាំអភិរក្ស និងគ្រប់គ្រងបរិដ្ឋាន។ បន្ទាប់មក នៅឆ្នាំ១៩៩៦ លេខាធិការដ្ឋាននេះបានប្រែក្លាយជាក្រសួងបរិស្ថាន។ នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថានបានត្រូវបង្កើតឡើង និងទទួលស្គាល់ជាផ្លូវការ ដោយអនុក្រឹត្យលេខ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧។ រីឯតម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩។

ការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ គឺតម្រូវឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដើម្បីចងក្រងជារបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ហើយរបាយការណ៍នេះគឺត្រូវឆ្លងកាត់ការពិនិត្យ និងផ្ដល់យោបល់ពីក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ មុននឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការអនុម័តលើគម្រោងអភិវឌ្ឍន៍។

ដើម្បីរួមចំណែកក្នុងការស្វែងយល់ ក៏ដូចជាការចូលរួមក្នុងសកម្មភាពនានាលើដំណើរការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានឲ្យមានប្រសិទ្ធភាព និងតម្លាភាព ក្រុមការងាររបស់សម្ព័ន្ធទន្លេកម្ពុជា និងក្រសួងបរិស្ថានបានសហការគ្នារៀបចំនូវកូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះ ក្រោមការគាំទ្រថវិកាពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជា។

កូនសៀវភៅនេះ ក៏អាចបង្ហាញពីដំណើរការនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយរួមបញ្ចូលទាំងការជ្រើសរើសគម្រោង ការកំណត់វិសាលភាព ការវាយតំលៃហេតុប៉ះពាល់ វិធានការកាត់បន្ថយ ការត្រួតពិនិត្យរបាយការណ៍ និងការ

តាមដានផែនការគ្រប់គ្រងបរិស្ថាន ក្នុងន័យពង្រឹងការចូលរួម និងពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ។

កូនសៀវភៅនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានគឺមានសារៈសំខាន់ណាស់សម្រាប់ឲ្យភាគីពាក់ព័ន្ធទាំងអស់ រួមមាន អ្នកធ្វើការសម្រេចចិត្ត ស្ថាប័នរបស់រាជរដ្ឋាភិបាល វិនិយោគិន ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សាធារណជន និងសហគមន៍រងផលប៉ះពាល់ពីគម្រោង ដើម្បីធ្វើការស្វែងយល់ និងចូលរួមយ៉ាងសកម្មក្នុងដំណាក់កាលនីមួយៗនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## ២. បទបញ្ញត្តិទាក់ទងនឹងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ដើម្បីអនុវត្តការវាយតំលៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ និងសម្រេចបានតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ច្បាប់ ក្រសួងបរិស្ថានត្រូវផ្អែកលើលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចខាងក្រោម៖

១.ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦

២.ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨

៣.អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩

៤.អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ឆ្នាំ១៩៩៩

៥.អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ឆ្នាំ១៩៩៩

៦.អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ឆ្នាំ២០០០

៧.ប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការកំណត់ថ្លៃសេវាការងារ សម្រាប់ការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើល ឆ្នាំ២០០០

៨.ប្រកាស ស្តីពីប្រតិភូកម្មអំណាចលើការធ្វើសេចក្តីសំរេចលើគម្រោងអភិវឌ្ឍន៍របស់មន្ទីរបរិស្ថានរាជធានី-ខេត្ត ឆ្នាំ២០០៥

៩. ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩។

## ៣. កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

### ៣.១. ស្ថាប័នទទួលខុសត្រូវ

ស្ថាប័នទទួលខុសត្រូវក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងបរិស្ថានតាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ។ ទោះបីយ៉ាងណា ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបានប្រកាសឲ្យប្រើជាផ្លូវការនៅខែធ្នូ ឆ្នាំ២០០៥។ នាយកដ្ឋាននេះត្រូវរាយការណ៍ទៅរដ្ឋមន្ត្រី តាមរយៈអគ្គនាយកដ្ឋានបច្ចេកទេស។ តួនាទី និងការទទួលខុសត្រូវសំខាន់គឺសំដៅលើការពិនិត្យលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ការអង្កេតតាមដាន និងការអនុវត្តនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍សាធារណៈ និងឯកជន។ ការអនុវត្តការងារផ្អែកសំខាន់ទៅលើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦ និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩។ ផ្អែកលើប្រកាស ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថានឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន នាយកដ្ឋានមានមន្ត្រីចំនួន ៤៩នាក់ ហើយរចនាសម្ព័ន្ធនៃនាយកដ្ឋានគឺមាន០៥ការិយាល័យ ដូចបង្ហាញក្នុងតារាងខាងក្រោម៖

**រចនាសម្ព័ន្ធនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន**



# ៣.២ គោលការណ៍ និងដំណាក់កាលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន



## ក. គម្រោងស្នើសុំ

ក្នុងដំណាក់កាលដំបូង ម្ចាស់គម្រោង/ក្រុមហ៊ុនវិនិយោគត្រូវលើកយកគម្រោងវិនិយោគរបស់ខ្លួនមកពិភាក្សាជាមួយក្រសួងបរិស្ថានឬមន្ទីរបរិស្ថានរាជធានី-ខេត្ត (ចំពោះទុនវិនិយោគក្រោមពីរលានដុល្លាអាមេរិក) ដោយភ្ជាប់មកនូវឯកសារទាក់ទងនឹងទីតាំងគម្រោង និងឯកសារពាក់ព័ន្ធនានា។

អ្វីដែលម្ចាស់គម្រោងចង់ដឹងក្នុងដំណាក់កាលនេះ តើគម្រោងវិនិយោគដែលក្រុមហ៊ុនបានស្នើមកក្រសួងបរិស្ថាន/មន្ទីរបរិស្ថានត្រូវបំពេញកាតព្វកិច្ចច្បាប់អ្វីខ្លះ?

ដូចនេះ ក្រសួងបរិស្ថាន (នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន) ឬមន្ទីរបរិស្ថាន បានធ្វើការផ្ទៀងផ្ទាត់ និងជ្រើសរើសគម្រោងទៅតាមល័ក្ខខ័ណ្ឌមួយចំនួនដូចចំណុច (ខ) ខាងក្រោម។

## ខ. ការជ្រើសរើសគម្រោង



ការជ្រើសរើសគម្រោងផ្អែកលើលិខិតបទដ្ឋានគតិយុត្ត និងការពិចារណាពីសញ្ញាណនៃហេតុប៉ះពាល់

ជាទូទៅ ការជ្រើសរើសគម្រោង (Screening) ត្រូវកំណត់ដោយក្រសួងបរិស្ថាន ហើយការជ្រើសរើសត្រូវផ្អែកទៅលើច្បាប់ ឬអនុក្រឹត្យដែលបានបញ្ជាក់ពី

ប្រភេទ និងទំហំនៃគម្រោងដែលត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

ករណីគម្រោងវិនិយោគទាំងនោះមិនមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ នៃលិខិតបទដ្ឋានគតិយុត្តទេ ក្រសួងបរិស្ថានអាចប្រើប្រាស់តារាងកំណត់ទំហំហេតុប៉ះពាល់ជំនួស។ តារាងកំណត់ទំហំនេះបង្ហាញឲ្យដឹងពីគម្រោងមួយត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមិនតម្រូវឲ្យធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានបញ្ជាក់លំអិតដូចខាងក្រោម៖

- តម្រូវឲ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញចំពោះគម្រោងដែលមានការប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ឬ
- តម្រូវឲ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគម្រោងដែលមានហេតុប៉ះពាល់បរិស្ថានមធ្យម ឬ
- ពុំតម្រូវឲ្យម្ចាស់គម្រោងធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ ចំពោះគម្រោងប្រភេទនេះមាន៣ប្រភេទគឺ៖

  ១.គម្រោងដែលរាជរដ្ឋាភិបាលកំណត់ថាជាប្រភេទគម្រោងពិសេស និងចាំបាច់បន្ទាន់។

  ២.តម្រូវឲ្យមានការរៀបចំផែនការគ្រប់គ្រងបរិស្ថាន។

  ៣.តម្រូវឲ្យរៀបចំជាកិច្ចសន្យាការពារបរិស្ថានចំពោះគម្រោងមិនជាប់នៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យ ឬគម្រោងដែលជាប់នៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យ ប៉ុន្តែគម្រោងនេះមានហេតុប៉ះពាល់បរិស្ថានអវិជ្ជមានតិចតួច ដូចជារោងចក្រកាត់ដេរសំលៀកបំពាក់ជាដើម។

## គ. ការកំណត់វិសាលភាព



ការពិភាក្សាលើល័ក្ខខ័ណ្ឌការងារ (Term of Reference)

ការកំណត់វិសាលភាព (Scoping) គឺជាដំណាក់កាលដំបូងនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បន្ទាប់ពីការជ្រើសរើស (Screening) គម្រោងបានបញ្ចប់។ ដំណាក់កាលកំណត់វិសាលភាពនេះ មានសារៈសំខាន់ណាស់នៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដើម្បីកំណត់នូវសមាសភាគមួយចំនួនខាងក្រោម៖

- កំណត់ប៉ារ៉ាម៉ែត្រដែលត្រូវសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- កំណត់ និងផ្តល់ព័ត៌មានដល់អ្នកពាក់ព័ន្ធ
- កំណត់ពីវិសាលភាពនៃការសិក្សា
- ឯកភាពលើវិធីសាស្ត្រនៃការចូលរួមជាសាធារណៈ និងវិធីសាស្ត្រនៃការសិក្សា
- កំណត់ពីសញ្ញាណនៃហេតុប៉ះពាល់ដើម្បីធ្វើការសិក្សា
- បង្កើតឲ្យមានល័ក្ខខ័ណ្ឌការងារ (Term of Reference)។

### តើអ្នកណាខ្លះដែលពាក់ព័ន្ធនៅក្នុងដំណាក់កាលកំណត់វិសាលភាពនេះ?

អ្នកដែលពាក់ព័ន្ធនៅក្នុងការកំណត់ទំហំវិសាលភាព នៃគម្រោងក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានមានដូចខាងក្រោម៖

- នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន
- ម្ចាស់គម្រោង
- ទីប្រឹក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងអ្នកជំនាញនានា
- ភ្នាក់ងារទទួលខុសត្រូវផ្សេងៗទៀត
- សាធារណជនដែលទទួលរងការប៉ះពាល់
- សាធារណជនដែលទទួលផលប្រយោជន៍ពីគម្រោង។

## ឃ. ការវិភាគហេតុប៉ះពាល់បរិស្ថាន



សកម្មភាពធ្វើអាជីវម្មរ៉ែដែលបង្កឲ្យមានការប៉ះពាល់

ក្នុងការវិភាគពីហេតុប៉ះពាល់បរិស្ថាន និងដំណាក់កាលវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញគឺតម្រូវឲ្យមានការវិភាគលើ៣ចំណុចគឺ(១).ការកំណត់ពីប្រភេទនៃហេតុប៉ះពាល់ (២).ការព្យាករណ៍ពីទំហំដែលនឹងកើតមានឡើង និងវិសាលភាពនៃហេតុប៉ះពាល់ និង (៣).ការកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់។

ហេតុប៉ះពាល់ទៅលើបរិស្ថាននាំឲ្យមានការផ្លាស់ប្តូរនូវទម្រង់បរិស្ថាន ដែលមានស្រាប់ ហើយហេតុប៉ះពាល់ទាំងនោះអាចជាហេតុប៉ះពាល់ដោយផ្ទាល់ និងប្រយោល ឬជាបណ្តុំ។ ការផ្លាស់ប្តូរអាចឃើញនៅក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងៗគ្នា (ប្រភេទនៃប្រព័ន្ធអេកូឡូស៊ី) និងកម្រិតសង្គម (ពីបុគ្គលទៅដល់សហគមន៍) ដែលអាចប្រែប្រួលហួសពីដែនកំណត់ ឬពេលវេលាសិក្សា ព្រមទាំងអាចកើតមានទាំងហេតុប៉ះពាល់អវិជ្ជមាន និងវិជ្ជមាន។

ការប៉ះពាល់ដោយផ្ទាល់ផ្អែកទៅលើការផ្លាស់ប្តូរសមាសភាគបរិស្ថាន ដែលកើតចេញពីអន្តរកម្មរវាងបរិស្ថាន និងសកម្មភាពគម្រោងផ្ទាល់។ ការប៉ះពាល់ដោយប្រយោលកើតចេញពីអន្តរកម្មរវាងបរិស្ថាន និងហេតុប៉ះពាល់ដោយប្រយោល។ បណ្តុំនៃហេតុប៉ះពាល់ផ្អែកទៅលើបណ្តុំនៃការផ្លាស់ប្តូរបរិស្ថាន ដោយមូលហេតុនៃសកម្មភាពមនុស្ស (ឧទាហរណ៍ អតីតកាល កំពុងដំណើរការ និងសកម្មភាពស្នើសុំរួមមានសកម្មភាពគម្រោងដែលកំពុងធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន)។ ការខូចខាតបរិស្ថាន ធ្វើឲ្យមានការផ្លាស់ប្តូរហួសហេតុទៅលើធនធានពាក់ព័ន្ធដែលមានស្រាប់ និងដាក់បន្ទុកកាន់តែធ្ងន់ថែមទៀតទៅលើសុខភាពមនុស្ស សត្វ និងបង្កើតជាគ្រោះមហន្តរាយនាពេលបច្ចុប្បន្ន ឬទៅថ្ងៃអនាគត។

## ខ. វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន

### តើវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាអ្វី?

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាសកម្មភាព ឬវិធានការជៀសវាង ឬធ្វើឲ្យមានការថយចុះនៃហេតុប៉ះពាល់បរិស្ថានអវិជ្ជមានពីសកម្មភាពគម្រោង។ វិធានការកាត់បន្ថយសំដៅទៅលើប្រព័ន្ធអេកូឡូស៊ី សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ផែនការ និងការអនុវត្តគម្រោងអាចរួមបញ្ចូលនូវវិធានការជាច្រើនវិធីសាស្រ្ត ឬជាច្រើនជម្រើសដូចមានរៀបរាប់ខាងក្រោម៖

- ការរៀបចំផែនការលើទីតាំង ឬពេលវេលានៃសកម្មភាព ដើម្បីជៀសវាងឥទ្ធិពលទៅលើធនធានជាក់លាក់មួយ ឬតំបន់ងាយទទួលរងការប៉ះពាល់

- ❖ បញ្ចូលនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន នៅក្នុងដំណាក់កាលរចនាគម្រោង ឬធ្វើផែនការ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានជាមុន
- ❖ ធានាការប់រងលើកម្មវិធីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដែលកើតឡើងទន្ទឹមគ្នាជាមួយនឹងគម្រោង
- ❖ ធានាការប់រងលើកម្មវិធីកាត់បន្ថយ បន្ទាប់ពីសកម្មភាពស្តារនូវធនធានដែលប៉ះពាល់ ឬតំបន់ដែលទទួលរងការប៉ះពាល់ ឬជំនួសនូវអ្វីដែលបាត់បង់ ឬធនធានដែលខូចខាតនៅក្នុងតំបន់រងការប៉ះពាល់ ឬតំបន់នានាដែលពាក់ព័ន្ធ។ ឧទាហរណ៍ ការបាត់បង់នូវប្រភេទត្រីទឹកសាបអាចកាត់បន្ថយ តាមរយៈការផ្តល់ពូជត្រី ឬការស្តារទន្លេដែលជាទីជំរករបស់ត្រីជាដើម។

## តើកំណត់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននៅពេលណា?

វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន អាចត្រូវបានកំណត់ក្នុងអំឡុងពេលមុនប្រតិបត្តិគម្រោង (ដំណាក់កាលរចនាគម្រោង និងសាងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង ដោយត្រូវពិនិត្យទៅលើកត្តាសំខាន់ៗដូចខាងក្រោម៖

- លទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ ឬបទពិសោធន៍កន្លងមកផ្តល់ជាវិធានការកាត់បន្ថយដែលត្រូវបានកំណត់ភ្លាមៗនៅក្នុងដំណាក់កាលរចនាគម្រោង និងការវាយតំលៃនៃគម្រោងស្នើសុំ។
- វិធានការកាត់បន្ថយអាចត្រូវបានបង្កើតឡើងក្នុងការឆ្លើយតបទៅនឹងហេតុប៉ះពាល់ជាក់លាក់ ដែលត្រូវបានកំណត់នៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងក្នុងដំណាក់កាលអនុវត្តគម្រោង។
- វិធានការអាចបង្កើតទៅជាការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរហូតដល់ការបញ្ចប់គម្រោង។

## ហេតុអ្វីត្រូវពិចារណាពីការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន នៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន?

ការធ្វើផែនការដ៏ប្រុងប្រយ័ត្ន និងការអនុវត្តគម្រោងទៅតាមផែនការគ្រប់គ្រងបរិស្ថានអាចកាត់បន្ថយ ឬជៀសវាងហេតុប៉ះពាល់បរិស្ថានអវិជ្ជមានដល់កម្រិតអប្បបរមា។ ផែនការនេះអាចត្រូវបានប្រតិបត្តិតាម ប្រសិនបើការបង្កើតនូវការកាត់បន្ថយត្រូវបានបញ្ចូលទៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានអាចជួយឲ្យឥទ្ធិពលអាក្រក់នឹងត្រូវបានកាត់បន្ថយ និងជួយផ្តល់ជាយោបល់ក្នុងការសម្រេចចិត្ត។ ការពិពណ៌នាពីប្រភព និងទំហំនៃសក្តានុពលហេតុប៉ះពាល់បរិស្ថាននៅក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាមូលដ្ឋានគ្រឹះ សម្រាប់រចនាការកាត់បន្ថយជាក់លាក់នៃឥទ្ធិពលអាក្រក់ទាំងនោះ។

ជាចុងបញ្ចប់ វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានត្រូវបានកំណត់នៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីអង្កេតតាមដានសកម្មភាពគម្រោងឲ្យមានប្រសិទ្ធភាព។

## តើនរណាជាអ្នកទទួលខុសត្រូវក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន?

ជាទូទៅ ភាគីស្នើសុំគម្រោង និងបង្កើតសកម្មភាពគម្រោងជានិច្ចកាលត្រូវទទួលខុសត្រូវក្នុងការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានដោយសហការ និងមានការចូលរួមពីអ្នកពាក់ព័ន្ធ។

ចុងបញ្ចប់ ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាចងក្រងពីវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។ របាយការណ៍នេះត្រូវបញ្ចូលនូវអ្វីដែលបានរកឃើញ និងសិក្សាដោយគោរពទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។ បន្ទាប់មក ម្ចាស់គម្រោង ត្រូវដាក់របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានមកក្រសួងបរិស្ថានដើម្បីពិនិត្យ និងផ្តល់យោបល់។

## ច. ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន

ផ្អែកលើអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបែងចែករបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាពីរ គឺ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។

ក្នុងការរៀបចំរបាយការណ៍នេះ ម្ចាស់គម្រោងអាចរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដោយខ្លួនឯងផ្ទាល់ ឬជួលក្រុមហ៊ុនទីប្រឹក្សាឯករាជ្យសម្រាប់រៀបចំរបាយការណ៍នេះ ដោយផ្អែកទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន។ ដោយឡែក ម្ចាស់គម្រោងអាចរៀបចំរបាយការណ៍ដោយខ្លួនឯងបាន នោះម្ចាស់គម្រោងត្រូវមានសមត្ថភាពជំនាញលើការងារវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងមានការទទួលស្គាល់ពីក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានចំពោះគម្រោងថ្នាក់រាជធានី-ខេត្ត ។

ចំណែកក្រុមហ៊ុនទីប្រឹក្សាត្រូវមានសមត្ថភាពជំនាញគ្រប់គ្រាន់ និងមានការទទួលស្គាល់ពីក្រសួងបរិស្ថានពីលក្ខណៈសម្បត្តិ ឬគុណភាពក្នុងការរៀបចំរបាយការណ៍។

ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលយ៉ាងតិច ០៣ខែ ដើម្បីសិក្សា និងប្រមូលទិន្នន័យដែលមានស្រាប់ (Secondary data) ទាក់ទងនឹងធនធានរូបសាស្ត្រ និងធនធានជីវសាស្ត្រ ព្រមទាំងការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍ជាតិ ប្រជាពលរដ្ឋរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។ ដោយឡែក ការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោង ឬក្រុមហ៊ុនទីប្រឹក្សាត្រូវចំណាយពេលចាប់ពី ០៦ខែឡើងទៅ ដើម្បីធ្វើការសិក្សា និងប្រមូលទិន្នន័យបឋម (Primary data) ដែលទាក់ទងនឹងធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគម្រោង ដូចជា អាជ្ញាធរដែនដី អង្គភាពពាក់ព័ន្ធ សហគមន៍មូលដ្ឋាន ប្រជាពលរដ្ឋទទួលរងការប៉ះពាល់ និងអ្នកពាក់ព័ន្ធនានា។

គំរូនៃរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ៖

- សេចក្តីសង្ខេប
- សេចក្តីផ្តើម
- ក្របខ័ណ្ឌច្បាប់
- ការពិពណ៌នាពីគម្រោង
- ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់
- ការចូលរួមជាសាធារណៈ
- ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ
- ផែនការគ្រប់គ្រងបរិស្ថាន
- ការវិភាគពីការខូចខាតបរិស្ថាន និងផលចំណេញផ្នែកសេដ្ឋកិច្ច (សម្រាប់តែរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ)
- សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

## ឆ. ការពិនិត្យ និងការធ្វើសេចក្តីសម្រេចលើរបាយការណ៍

ជាគោលការណ៍ច្បាប់ ក្រសួងបរិស្ថានមានតួនាទីជាអ្នកពិនិត្យលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងផ្តល់ការឯកភាព ឬមិនឯកភាពលើរបាយការណ៍នេះ។

រយៈពេលនៃការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងអភិវឌ្ឍន៍មានរយៈពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបរិស្ថានបានទទួលរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងរបាយការណ៍សិក្សាបុរេ/សមិទ្ធិលទ្ធភាពគម្រោង។

នីតិវិធីក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញនៅក្នុងក្រសួងបរិស្ថានមានដូចខាងក្រោម៖

- កិច្ចប្រជុំរបស់មន្ត្រីជំនាញរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន(EIA) និងការចុះពិនិត្យទីតាំងជាក់ស្តែងមានចំនួន១០ថ្ងៃ។

- ❖ កិច្ចប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ថ្ងៃ
- ❖ កិច្ចប្រជុំថ្នាក់ដឹកនាំរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ថ្ងៃ
- ❖ កិច្ចប្រជុំអន្តរក្រសួងមានរយៈពេល ០៥ថ្ងៃ ដែលមានការចូលរួមពីក្រសួង/ស្ថាប័ន អាជ្ញាធរដែនដី អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនឹងគម្រោងវិយោគដោយមាន **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** ជាប្រធានអង្គប្រជុំ។
- ❖ ការរៀបចំលិខិតផ្តល់យោបល់៖ ក្នុងរយៈពេល ០៥ថ្ងៃចុងក្រោយ មន្ត្រីនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាលបរិស្ថានរៀបចំលិខិតផ្តល់យោបល់ ដោយបញ្ចូលនូវមតិយោបល់របស់កិច្ចប្រជុំទាំង០៤ខាងលើដើម្បីឲ្យម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សាកែតម្រូវឡើងវិញនូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

បន្ទាប់ពីបានការអនុញ្ញាតពី **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** រួចមកនាយកដ្ឋាន EIA បានបង្កើតក្រុមការងារពិនិត្យរបាយការណ៍ដោយមានមន្ត្រីជំនាញនាយកដ្ឋាន EIA យ៉ាងតិចចំនួន០៤រូប សម្រាប់ទទួលខុសត្រូវលើការពិនិត្យរបាយការណ៍ ការចុះពិនិត្យទីតាំងជាក់ស្តែង និងចាត់ចែងការងារផ្សេងៗដែលពាក់ព័ន្ធនឹងគម្រោងវិនិយោគនេះ។

បន្តទៀត នាយកដ្ឋានរៀបចំកិច្ចប្រជុំអន្តរនាយកដ្ឋានរបស់ក្រសួងបរិស្ថានដោយកិច្ចប្រជុំនេះស្ថិតនៅក្រោមអធិបតីភាពរបស់ ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋាន EIA ជាប្រធានអង្គប្រជុំ ដោយមានការចូលរួមពីឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋាន EIA អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នាយកដ្ឋាន EIA នាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន នាយកដ្ឋានផែនការនិងកិច្ចការច្បាប់ នាយកដ្ឋានអប់រំនិងផ្សព្វផ្សាយព័ត៌មាន នាយកដ្ឋានវាយតំលៃធនធានធម្មជាតិនិងទិន្នន័យ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនទីប្រឹក្សា។ រាល់មតិ និងយោបល់របស់ប្រធានអង្គប្រជុំ និងសមាជិកអង្គប្រជុំត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ។

បន្ទាប់មកទៀត នាយកដ្ឋាន EIA បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងបរិស្ថាន ដោយកិច្ចប្រជុំនេះស្ថិតនៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** ជាប្រធានអង្គប្រជុំ ដែលមានការចូលរួមពីឯកឧត្តមរដ្ឋលេខាធិការក្រសួងបរិស្ថានទាំងអស់ ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋាន EIA ឯកឧត្តមអគ្គនាយកបច្ចេកទេស នាយកដ្ឋាន EIA ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនទីប្រឹក្សា។ ការផ្តល់មតិ និងយោបល់របស់ថ្នាក់ដឹកនាំក្រសួងទាំងអស់ត្រូវបានកត់ត្រាចូលក្នុងកំណត់ហេតុ។

បន្ទាប់មក នាយកដ្ឋាន EIA បានរៀបចំកិច្ចប្រជុំអន្តរក្រសួងដោយមានការចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធនឹងគម្រោង ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សាលារាជធានី-ខេត្ត មន្ទីរបរិស្ថានរាជធានី-ខេត្ត តំណាងអង្គការមិនមែនរដ្ឋាភិបាល តំណាងប្រជាពលរដ្ឋរងផលប៉ះពាល់ ក្រុមហ៊ុនវិនិយោគ ក្រុមហ៊ុនទីប្រឹក្សា និងអ្នកពាក់ព័ន្ធនានានឹងគម្រោងអភិវឌ្ឍន៍នេះ។ កិច្ចប្រជុំអន្តរក្រសួងនេះគឺស្ថិតនៅក្រោមអធិបតីភាពរបស់ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន** ជាប្រធានអង្គប្រជុំ។

បន្ទាប់ពីនីតិវិធីនៃការផ្តល់យោបល់ចប់សព្វគ្រប់ ក្រសួងបរិស្ថានបានចងក្រងរាល់ការផ្តល់យោបល់គ្រប់កិច្ចប្រជុំទាំងអស់ បញ្ជូនទៅឲ្យក្រុមហ៊ុនធ្វើការកែតម្រូវលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ក្នុងករណី ក្រុមហ៊ុនកែតម្រូវពុំបានត្រឹមត្រូវតាមលិខិតផ្តល់យោបល់របស់ក្រសួងបរិស្ថាន នោះក្រសួងបរិស្ថានមិនចេញលិខិតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញទេ។

នៅពេលក្រុមហ៊ុនបានកែតម្រូវបានត្រឹមត្រូវតាមការផ្តល់យោបល់ របស់ក្រសួង នោះក្រសួងបរិស្ថានចេញលិខិតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង/ពេញលេញ ដោយតម្រូវឲ្យក្រុមហ៊ុនធ្វើកិច្ចសន្យាការពារបរិស្ថាន

បន្ថែមទៀតជាមួយក្រសួងបរិស្ថាននូវល័ក្ខខ័ណ្ឌផ្សេងៗ ដែលពុំមានបញ្ជាក់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។



ការឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន

នៅពេលក្រុមហ៊ុនទទួលលិខិតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានជាស្ថាពរ ម្ចាស់គម្រោងអាចដំណើរការសកម្មភាពអាជីវកម្មរបស់ខ្លួនបានទៅតាមផែនការគ្រប់គ្រងបរិស្ថាន និងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ដូចមានចែងនៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

## ៥. ការអង្កេតតាមដានគម្រោង

ជាបន្តទៀត ម្ចាស់គម្រោងត្រូវអនុវត្តទៅតាមផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល៦ខែ បន្ទាប់ពីក្រសួងបរិស្ថានបានឯកភាពលើរបាយការណ៍នេះ។ យោងតាមអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ស្ថាប័នអនុម័តគម្រោងត្រូវណែនាំដល់ម្ចាស់គម្រោងឲ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ដូចមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពដោយក្រសួងបរិស្ថាន។

ការអង្កេតតាមដានគម្រោងត្រូវពិនិត្យទៅលើហេតុប៉ះពាល់ ការផ្ទៀងផ្ទាត់នៃ

ការព្យាករណ៍ និងការឆ្លើយតបទៅនឹងវិធានការកាត់បន្ថយ ដូចដែលមានបញ្ជាក់នៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន។

ក្រសួងបរិស្ថានមានភារកិច្ចតាមដាន ឃ្លាំមើល និងចាត់វិធានការឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង ដូចមានចែងនៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដែលបានអនុម័តរួច។

ទន្ទឹមនឹងនេះដែរ ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍ត្រួតពិនិត្យបរិស្ថានរៀងរាល់០៣ខែ ឬ០៦ខែម្តង មកនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃក្រសួងបរិស្ថាន ដូចមានរៀបរាប់នៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ដើម្បីពិនិត្យ និងផ្តល់យោបល់។

ករណីម្ចាស់គម្រោងមិនអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាន ក្រសួងបរិស្ថានសហការជាមួយក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ឈប់សកម្មភាពដែលកំពុងដំណើរការ ឬមានស្រាប់របស់ម្ចាស់គម្រោង ទៅតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

## ឈ. ការចូលរួមជាសាធារណៈ:



ការចូលរួមពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋទទួលរងការប៉ះពាល់ពីគម្រោង

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានធានានូវប្រសិទ្ធភាព នៃការចូលរួមជាសាធារណៈ ហើយលក្ខណៈពិសេសតែមួយគត់នៃវប្បធម៌ សេដ្ឋកិច្ច សង្គម និងកត្តាផ្សេងៗដែលដាច់ឆ្ងាយត្រូវបានយកមកពិចារណានៅក្នុងការធ្វើផែនការ និងការអនុវត្តលើការពិគ្រោះយោបល់ជាសាធារណៈ។

ដូចមានចែងនៅក្នុងមាត្រា១៦ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ បានលើកឡើងថា ក្រសួងបរិស្ថានត្រូវផ្តល់ទៅតាមសំណើពីសាធារណជននូវព័ត៌មាននៃសកម្មភាពនានា និងជម្រុញឲ្យមានការចូលរួមជាសាធារណៈនៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

នៅក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគម្រោងអភិវឌ្ឍន៍ការចូលរួមជាសាធារណៈត្រូវធ្វើឡើងនៅក្នុងដំណាក់កាលសំខាន់០៣ គឺ៖

- ❖ ដំណាក់កាលកំណត់ទំហំគម្រោង
- ❖ ដំណាក់កាលពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន
- ❖ ដំណាក់កាលអង្កេតតាមដានគម្រោង។

ការចូលរួម ឬការពិគ្រោះយោបល់ជាសាធារណៈ ក៏អាចប្រព្រឹត្តទៅនៅក្នុងដំណាក់កាលផ្សេងៗក្រៅពីដំណាក់ទាំង០៣ខាងលើនេះដែរទៅតាមតម្រូវការចាំបាច់របស់អ្នកពាក់ព័ន្ធ។

អ្នកដែលពាក់ព័ន្ធក្នុងការចូលរួមជាសាធារណៈ នៃកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានមាន៖

- ❖ ក្រសួង/ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ❖ ម្ចាស់គម្រោង និងអ្នកមានផលប្រយោជន៍នៅក្នុងគម្រោង
- ❖ អង្គការមិនមែនរដ្ឋាភិបាល
- ❖ ម្ចាស់ជំនួយ និងផ្នែកឯកជន
- ❖ ប្រជាពលរដ្ឋរងការប៉ះពាល់។

ចំពោះខ្លឹមសារលំអិតស្តីពីការចូលរួមជាសាធារណៈ នាយកដ្ឋានអង្កេតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាននឹងរៀបចំជាឯកសារ ដែលមានលក្ខណៈជាបទដ្ឋានបច្ចេកទេស ឬច្បាប់ ដាច់ដោយឡែកមួយទៀត។

## ៤. សេចក្តីសន្និដ្ឋាន

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានគឺផ្អែកទៅលើបទដ្ឋានគតិយុត្តនានាដែលមានស្រាប់ ដោយតម្រូវឲ្យរាល់គម្រោងអភិវឌ្ឍន៍ទាំងសាធារណៈ និងឯកជនត្រូវតែធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននឹងចាប់ផ្តើមដំណើរការសាងសង់ ឬធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួន។

ការអភិវឌ្ឍទាំងឡាយណា ដែលមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានគឺអាចជួយកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់ធនធានបរិស្ថាន សង្គម និងសេដ្ឋកិច្ច ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងចូលរួមធានាការអភិវឌ្ឍប្រកបដោយចីរភាព។

លើសពីនេះទៀត ការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាការផ្តល់ឱកាសដ៏ប្រសើរសម្រាប់ឲ្យមានការចូលរួមពីសាធារណជនគ្រប់លំដាប់ថ្នាក់ រួមមាន ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាល សហគមន៍ ប្រជាពលរដ្ឋរងការប៉ះពាល់ ម្ចាស់គម្រោង និងអ្នកពាក់ព័ន្ធនានា។

# ឯកសារយោង

- ច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន ខែមករា ឆ្នាំ១៩៩៦
- ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ខែធ្នូ ឆ្នាំ១៩៩៦
- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ខែកញ្ញា ឆ្នាំ១៩៩៧
- អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ខែសីហា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹក ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង ខែមេសា ឆ្នាំ១៩៩៩
- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង ឆ្នាំ២០០០
- ប្រកាសរួមរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់ថ្លៃសេវាការងារសម្រាប់ការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើល ឆ្នាំ២០០០
- ប្រកាស ស្តីពីប្រតិភូកម្មអំណាចលើការធ្វើសេចក្តីសម្រេចលើគម្រោងអភិវឌ្ឍន៍របស់មន្ទីរបរិស្ថានរាជធានី-ខេត្ត ឆ្នាំ២០០៥
- ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ឆ្នាំ២០០៩។
- UNEP's Environmental Impact Assessment, Training Resource Manual-Second Edition, May 2002.

## ឧបសម្ព័ន្ធ
## ការពន្យល់ន័យ

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង** (**វ.ហ.ប.ដ.**)៖ គឺជាការសិក្សាដំបូងលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនពឹងផ្អែកទៅលើទិន្នន័យមានស្រាប់ដែលមាននៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោងសំដៅរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានឲ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឲ្យដល់កម្រិតអតិបរមា។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ** (**វ.ហ.ប.ព.**)៖ គឺជាការសិក្សាលំអិតលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ដោយភាគច្រើនពឹងផ្អែកទៅលើទិន្នន័យចំបង ដែលមាននៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ វិភាគនូវសក្តានុពល និងបណ្តុំនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គម្រោង សំដៅរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានឲ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឲ្យដល់កម្រិតអតិបរមា ព្រមទាំងវិភាគការខូចខាតបរិស្ថាន និងផលចំណេញនៃសេដ្ឋកិច្ចរបស់គម្រោងអភិវឌ្ឍន៍។

**កិច្ចសន្យាការពារបរិស្ថាន** (**ក.ក.ប.**)៖ គឺជាការព្រមព្រៀងគ្នាដែលបានបង្កើតឡើងដោយភាគីម្ចាស់គម្រោង និង ភាគីក្រសួងបរិស្ថាន ដើម្បីការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។

**លិខិតឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន** (**ល.ឯ.រ.ប.**)៖ គឺជាលិខិតដែលអនុញ្ញាតដោយក្រសួងបរិស្ថាន ដើម្បីទទួលស្គាល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

**ផែនការគ្រប់គ្រងបរិស្ថាន** (ផ.គ.ប.)៖ គឺជាកម្មវិធីត្រួតពិនិត្យបរិស្ថានដូចមាននៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលបានរៀបចំឡើងដោយម្ចាស់គម្រោង និងមានការឯកភាពពីក្រសួងបរិស្ថាន។

**ការអង្កេតតាមដានបរិស្ថាន**(អ.ត.ប.)៖ គឺជាការពិនិត្យតាមដាន និងការវាយតំលៃលើការអនុវត្តកិច្ចដំណើរការត្រួតពិនិត្យបរិស្ថាន ដើម្បីធ្វើការកំណត់ពីលក្ខណៈវិនិច្ឆ័យនៃគុណភាពបរិស្ថាន ដូចបានឯកភាពជាផ្លូវការនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

**ការចូលរួមជាសាធារណៈ** (ក.ច.សា.)៖ គឺជាការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធទៅនឹងគម្រោងអភិវឌ្ឍន៍ដែលអ្នកពាក់ព័ន្ធទាំងនោះ រួមមាន ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ ម្ចាស់ក្រុមហ៊ុន ក្រុមហ៊ុនទីប្រឹក្សា តំណាងប្រជាពលរដ្ឋដែលទទួលរងនូវការប៉ះពាល់ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធនឹងតំបន់គម្រោង។

**ការផ្សព្វផ្សាយជាសាធារណៈ** (ផ.ផ.សា)៖ គឺជាការផ្តល់នូវព័ត៌មានដល់សាធារណជនពី វត្តមានគម្រោងអភិវឌ្ឍន៍ កិច្ចព្រមព្រៀង ការអំណះអំណាង ផែនការគ្រប់គ្រង ឬរបាយការណ៍នៃសញ្ញាណហេតុប៉ះពាល់ដែលត្រូវបានធ្វើឬបំពេញ និងអាចរកបានជាសាធារណៈនិងស្ម័គ្រចិត្ត។

**ម្ចាស់គម្រោង** (ម.គ.)៖ គឺជាម្ចាស់កម្មសិទ្ធិ ឬ អ្នកអភិវឌ្ឍន៍គម្រោង ឬ រាល់រូបវន្តបុគ្គល នីតិបុគ្គល ឬអង្គការ ដែលមានការអនុញ្ញាតក្នុងការសិក្សា រុករក រចនាសាងសង់ និងអនុវត្តគម្រោង។ ម្ចាស់គម្រោងជាផ្នែកឯកជន រដ្ឋាភិបាល ឬ អង្គការដែលទទួលខុសត្រូវសម្រាប់គម្រោងអភិវឌ្ឍន៍។

**នាយកដ្ឋាន** EIA៖ នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន។